C29

Prepared by CRS-KH Ag team 2004

# អង្គការ ស៊ី អារ អែស

## គំរោង កសិកម្មស្វាយរៀង

# ការគ្រប់គ្រងជីជាតិដី សំរាប់ដំណាំស្រូវ



ចងក្រងឯកសារដោយក្រុមអ្នកបច្ចេកទេសកសិកម្ម អង្គការ ស៊ី អារ អែស

គំរោង កសិកម្មស្វាយរៀងឆ្នាំ ២០០៤

## មាតិកាអត្ថបទ

ទំព័រ

I. សេចក្តីផ្តើម..........១
II. គោលបំណង..........១
III. ប្រភេទនៃការគ្រប់គ្រងជីជាតិ
១.ដំណាំបង្វិល..........២
២.ដំណាំជីស្រស់
ក.ពពួកជីស្រស់ដាំក្នុងស្រែ..........៣
ខ.ពពួកជីស្រស់ដាំលើភ្លឺស្រែ..........៤
៣.ការលុបគល់ជញ្ជ្រាំង..........៥
៤.ការពន្លិចទឹក..........៦
៥.ជីកំប៉ុស្ត..........៧
៦.ពពួកបណ្តង្គជាតិ..........៨

## I. សេចក្តីផ្តើម

ការគ្រប់គ្រង និង បង្កើនជីជាតិដីតាមរយៈការដាក់ជីធម្មជាតិមានសារៈសំខាន់ណាស់ ដើម្បី រក្សាគុណភាពដី សំរាប់ដំណាំស្រូវអោយបានទទួលនូវទិន្នផល និង មានស្ថេរភាពខ្ពស់ ។ ជាងនេះទៅ ទៀត កង្វះខាតជីធម្មជាតិធ្វើអោយយើងប្រើជីគីមីជំនួសហើយធើអោយដីស្រែ ហិលជីជាតិយ៉ាង លឿន និង ចំណាយច្រើន។ ដូចនេះការគ្រប់គ្រងដីស្រែដើម្បីរក្សានូវគុណ ភាព និង ការបង្កើន បន្ថែមនូវ ជីធម្មជាតិគឺជាវិធីសាស្ត្រសមស្របដែលកសិករពុំអាចខ្វះបាន ។

## II. គោលបំណង:

- ដើម្បីអោយបង្កលក្ខណៈអោយពពួកសត្វល្អិតបំបែកធាតុតូចៗរស់នៅស៊ីកំទេចធ្វើអោយ ពុកផុយរលួយក្លាយជាជី។
- កែឆ្នៃ និង ប្រើប្រាស់ធនធានក្នុងស្រុកអោយអស់លទ្ធភាព ដើម្បីកាត់បន្ថយការចំណាយ លុយ ទិញជីគីមី យកមកប្រើនាំអោយខូចដីស្រែ ។
- បង្កើន និង រក្សាគុណភាពផលិតផលស្រូវសំរាប់អាហាររូបត្ថម្ភ និង តំលៃសំរាប់ទីផ្សារ ។

## III. ប្រភេទនៃការគ្រប់គ្រងជីជាតិដី:

### ១. ដំណាំបន្ទាប់:

យើងអាចដាំដំណាំផ្សេងៗសំរាប់យកផលក្រោយពេលច្រូតកាត់ស្រូវរួចដូចជា:- សណ្តែក ដំឡូង ឪឡឹក ល្ពៅ ត្រសក់ស្រូវ......។ល.។ រួចដល់រដូវវស្សាគេស្ទូង ស្រូវលើដីស្រែ ដីដែលនោះ ព្រោះមាន ជីជាតិមួយចំនួនធំស្រាប់ក្នុងដីរួចទៅហើយដោយបានមកពីរ ការបន្សល់ ទុករបស់ដំណាំ មុន ។






ឯកសារយោង:

.កម្មវិធីបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម-អង្គការ ស៊ីដសេ(CIDSE)

## ២. ដំណាំជីស្រស:

### ក. ពពួកដាំក្នុងវាលស្រែ:

មានរុក្ខជាតិជាច្រើនមានលទ្ធភាពចាប់អាហារធាតុចិញ្ចឹម( អាសូត) ពីបរិយាកាសហើយផ្ទុកក្នុងខ្លួនរបស់វាដូចជាពពាយដាវ ពពួកសណ្តែក និង ពពួកស្នោរ ដូច្នេះគេអាចដាំវាក្នុងស្រែទុករហូតដល់វាចេញផ្ការជាអតិបរិមាទើបគេកាប់ជព្រាំ ឬ ភ្ជួលុបទៅក្នុងដីមុនពេលស្ទូងបាន។



## ខ. ពពួកដាំលើភ្លឺស្រែ

ពពួករុក្ខជាតិពហុប្រយោជន៍ខ្លះទៀតដូចជា អង្កាញ់ សង្កែ កន្ទំធេត អំពិលបារាំង .... ។ល។ គេអាចដាំលើភ្លឺស្រែហើយនៅរៀងរាល់ដើមរដូវវស្សាពេលមានលាស់ស្លឹកខ្ចីច្រើនគេអាចកាប់មែកធ្វើអុសដុតហើយស្លឹកស្រស់ដាក់ផ្ទាល់រួចភ្ជួរលុបក្នុងស្រែតែម្តង ។



## ៣. ការលុបជញ្រាំង:

ក្រោយពីច្រូតកាត់រួចពេលទឹកកំពុងមានទឹកក្នុងស្រែគេត្រូវភ្ជួរលុបជញ្រាំងបង្កប់ក្នុងដីស្រែ ដើម្បីអោយវា ពុកផុយរលួយក្លាយជាជី និង បង្កលក្ខណៈអោយសត្វល្អិតតូចៗបានរស់នៅធ្វើអោយ ដីធូរ មានជីជាតិ និង បង្កប់នូវពងសត្វល្អិតចង្រៃ។



## ៤. ការពន្លិចទឹក:

ចំពោះកសិករដែលមានលទ្ធភាព អាចបូម ឬ ប្រើវិធីផ្សេងៗដើម្បីអោយទឹកដក់នៅក្នុងស្រែដែល ធ្វើអោយដីសើមជាប្រចាំ មានល្បប់-មានសត្វល្អិតរស់នៅ និងបង្កើន អាហារធាតុផ្សេងៗទៀត។



## ៤. ជីកំប៉ុស្តិ៍:

ដាក់ជីកំប៉ុស្តទ្រាប់បាត ឬ បំប៉នសំណាបឬស្រែសំរាប់ស្ទូងចំនួន ពី ១០តោន ទៅ១៥តោន សំរាប់ផ្ទៃដីក្នុងមួយហិកតា ហើយបើសិនជាមានជីតិច ត្រូវបែងជីជាប្លង់សំរាប់ឆ្នាំទីមួយ ឆ្នាំទីពីរ ឆ្នាំទីបី និង ឆ្នាំទីបួន ហើយឆ្នាំទីប្រាំត្រូវដាក់នៅកូនស្រែដែលបានដាក់កាលពីឆ្នាំដំបូងវិញព្រោះវា មានប្រសិទ្ធភាពរហូតដល់៤ឆ្នាំព្រោះវាបានមកពីការពុកផុយរលួយរបស់រុក្ខជាតិ ផេះ និងលាមក ដែលពុំមានសារធាតុគីមី ។



## ៦. ពពួកបណ្ដុជាតិ:

គេអាចដាំពពួកបណ្ដុជាតិដូចជាចកគ្រប់ប្រភេទលាយឡំគ្នាជាមួយដំណាំស្រូវក្នុងស្រែតែមួយ រួចរក្សាវាទុកដើម្បីអោយវាចាប់ធាតុអាសូតពីបរិយាកាសសំរាប់ចិញ្ចឹម និង ផ្ទុកក្នុងដើមដងរបស់វា ធ្វើអោយគុម្ពស្រូវដែលនៅក្បែរអាចស្រូបជណ្ដើមយកអាសូតទាំងនោះទៅចិញ្ចឹមដើមដងវា ។






ឯកសារយោង:

.កម្មវិធីបណ្ដុះបណ្ដាលបច្ចេកទេសកសិកម្ម-អង្គការ ស៊ីដសេ(CIDSE)